សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association




# របាយការណ៍ឃ្លាំមើលប្រចាំត្រីមាសស្ដីពី
# ស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជា

ខែតុលា - ធ្នូ ឆ្នាំ២០២៣ | លេខចេញផ្សាយ ១០

# មាតិកា


**១.** សេចក្តីផ្តើម និងសេចក្តីសង្ខេប........................................ ៤

a. សេចក្តីសង្ខេបនៃឧប្បត្តិហេតុទាំងអស់នៃការយាយីទៅលើអ្នកសារព័ត៌មានដែលបាន កត់ត្រាពីខែតុលាដល់ ខែធ្នូឆ្នាំ ២០២៣........................................ ៤

b. ទីកន្លែងឧប្បត្តិហេតុ........................................ ៤

**២.** បរិបទក្នុងត្រីមាសនេះ........................................ ៦

**៣.** ឧប្បត្តិហេតុរាយការណ៍ក្នុងត្រីមាសនេះ........................................ ៨

**៤.** ការធ្វើបច្ចុប្បន្នភាពសំខាន់ៗ........................................ ១៧

# សេចក្ដីផ្ដើម និងសេចក្ដីសង្ខេប

អ្នកសារព័ត៌មាននៅកម្ពុជានៅតែប្រឈមនឹងការយាយីនៅពេលដែលពួកគេព្យាយាមរាយការណ៍ព័ត៌មានអំពីបញ្ហារសើប និងព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងប្រទេស។

រូបភាពនៃការគំរាមកំហែងដោយពាក្យសំដី ការគំរាមកំហែងតាមផ្លូវច្បាប់ និងរាងកាយ បានបន្តប៉ះពាល់ដល់សេរីភាពសារព័ត៌មាន។

សម្រាប់ខេមបូចា យើងជឿថា វាចាំបាច់ណាស់ក្នុងការរាយការណ៍អំពីករណីនៃការយាយីទាំងនេះ។ ខេមបូចា សង្ឃឹមថានឹងជំរុញឲ្យមានបរិយាកាសសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការនិយាយស្ដីសម្រាប់អ្នកសារព័ត៌មានទាំងអស់ដែលនឹងអាចរាយការណ៍ដោយបើកចំហដោយមិនបារម្ភពីសុវត្ថិភាពពួកគេ ឬសុវត្ថិភាពអ្នកនៅជុំវិញខ្លួនពួកគេ។

របាយការណ៍ប្រចាំត្រីមាសរបស់ខេមបូចា មានតួនាទីជាឧបករណ៍សំខាន់មួយក្នុងការកត់ត្រា និងវាយតម្លៃនិន្នាការ និងព្រឹត្តិការណ៍វិវឌ្ឍន៍ថ្មីៗនៃស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា។ វាគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបន្តរបស់យើងក្នុងការឃ្លាំមើល និងតស៊ូមតិដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។

នៅក្នុងរបាយការណ៍នេះ រួមមានសចក្ដីសង្ខេបខ្លីៗនៃឧប្បត្តិហេតុ និងព័ត៌មានបច្ចុប្បន្នភាពទាក់ទងនឹងសេរីភាពសារព័ត៌មាន សេរីភាពនៃការបញ្ចេញមតិ និងការរួចផុតពីការយាយី។

សេរីភាពសារព័ត៌មាន គឺជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់ប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យ។ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យ ដើរតួជាអ្នកឃ្លាំមើលក្នុងការជំរុញឲ្យអ្នកមានអំណាចទទួលខុសត្រូវ លើកកម្ពស់តម្លាភាព និងលើកទឹកចិត្តឱ្យមានលំហូរព័ត៌មានដោយសេរី ដែលចេញពីទស្សនៈចម្រុះ។ សេរីភាពសារព័ត៌មានផ្ដល់សិទ្ធិអំណាចដល់ពលរដ្ឋ ដោយផ្ដល់ព័ត៌មានត្រឹមត្រូវ និងអាចជឿទុកចិត្តបានដល់ពួកគេ។

នៅត្រីមាសនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់នៃការបំភិតបំភ័យផ្នែកផ្លូវច្បាប់។ អ្នកសារព័ត៌មានត្រូវបានចាប់ឃុំខ្លួន ដាក់ពន្ធនាគារ និងរងបណ្ដឹង ដោយមានចំនួនកើនឡើងបើធៀបនឹងត្រីមាសមុនៗ។ យើងបានកត់ត្រាឧប្បត្តិហេតុនេះយ៉ាងហោចណាស់៤ករណី ដែលកើតឡើងមកលើអ្នកសារព័ត៌មាននៅត្រីមាសនេះ។

លើសពីនេះទៀត យើងក៏បានកត់ត្រាមួយករណីនៃការយាយីលើរាងកាយដោយហិង្សា។ អ្នកសារព័ត៌មានអនឡាញម្នាក់ត្រូវក្រុមមនុស្ស ដែលគេស្គាល់ថា ជាឈ្មួញរកស៊ីឈើនៅខេត្តកំពង់ចាម ចាប់ចងដៃចងជើងក្រោមហេតុផលថាបានចូលទៅទីតាំងឯកជន។ នេះជាហេតុការណ៍ដ៏ធ្ងន់ធ្ងរមួយនៃការប្រើហិង្សាទៅលើអ្នកសារព័ត៌មាន និងជាគ្រោះថ្នាក់សម្រាប់អ្នកសារព័ត៌មាននៅពេលរាយការណ៍ព័ត៌មាន។ ការវាយប្រហារបែបនេះមិនគួរកើតឡើងចំពោះអ្នកសារព័ត៌មាននោះទេ។ ប៉ុន្តែនេះជាការពិត ដែលកើតឡើងចំពោះអ្នកសារព័ត៌មាននៅទីនេះរួចទៅហើយ។

ព្រឹត្តិការណ៍វិវឌ្ឍន៍សំខាន់ៗ ដែលយើងបានកត់ត្រាក្នុងត្រីមាសនេះ រួមមានការបិទកាសែតជាភាសាខ្មែរដ៏ចំណាស់ជាងគេមួយនៅក្នុងប្រទេស ការកាត់ទោសអ្នកសារព័ត៌មានអនឡាញម្នាក់ឱ្យជាប់ពន្ធនាគារពីរឆ្នាំ និង

បំណងរបស់រដ្ឋាភិបាលក្នុងការបង្កើតក្រុមត្រួតពិនិត្យមួយជាមួយនឹងការដាក់ចេញនូវអនុសាសន៍សម្រាប់វិស័យប្រព័ន្ធផ្សព្វផ្សាយ។

នៅក្នុងត្រីមាសនេះ ដែលរាប់ចាប់ពីខែតុលា ដល់ ខែធ្នូ ឆ្នាំ២០២៣ ខេមបូចា បានកត់ត្រាករណីយាយីមកលើអ្នកសារព័ត៌មានចំនួន ៨ករណី ដែលប៉ះពាល់ទៅលើអ្នកសារព័ត៌មាន ៩នាក់។ ដូចគ្នានេះដែរ នៅក្នុងរបាយការណ៍នេះ យើងបានធ្វើបច្ចុប្បន្នភាពអំពីបញ្ហា ដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកំពុងប្រឈម និងនិន្នាការនៃសេរីភាពនៃការបញ្ចេញមតិ និងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយ។

គោលបំណងរបស់យើងគឺ ទទួលស្គាល់ កត់ត្រា និងដោះស្រាយបញ្ហា ដែលអ្នកសារព័ត៌មានកំពុងប្រឈមតាមរយៈរបាយការណ៍នេះ។ អ្នកសារព័ត៌មាន មានសិទ្ធិធ្វើការដោយគ្មានការភ័យខ្លាច។ នៅពេលលោកអ្នកអានរបាយការណ៍នេះ យើងសូមលើកទឹកចិត្តដល់លោកអ្នកចុះបញ្ជាំងពីស្ថានភាពរបស់អ្នកសារព័ត៌មាននៅកម្ពុជា និងសារៈសំខាន់នៃសេរីភាពសារព័ត៌មាន។

# បរិបទក្នុងត្រីមាសនេះ

## សេចក្ដីសង្ខេបនៃឧប្បត្តិហេតុទាំងអស់នៃការយាយីទៅលើអ្នកសារព័ត៌មានដែលបានកត់ត្រាពីខែតុលាដល់ ខែធ្នូឆ្នាំ ២០២៣៖

៣ករណី
ការបំភិតបំភ័យតាមផ្លូវច្បាប់




៤ករណី
ការបំភិតបំភ័យតាមតាមពាក្យសម្ដី



១ករណី
ហិង្សាលើរូបរាងកាយ



## ទីកន្លែងឧប្បត្តិហេតុ



**១៧ ធ្នូ — ស្ទឹងត្រែង**

ចាងហ្វាងសារព័ត៌មានអនឡាញជាប់ពន្ធនាគារពីបទចោទថាបានទន្ទ្រានដីព្រៃរបស់រដ្ឋ

**៤ ធ្នូ — ភ្នំពេញ**

ចាងហ្វាងសារព័ត៌មានអនឡាញជាប់ពន្ធនាគារពីបទចោទលួចចូលទៅក្នុងប្រព័ន្ធទិន្នន័យ

**២ ធ្នូ — កំពង់ចាម**

អ្នកសារព័ត៌មានអនឡាញម្នាក់រងអំពើហឹង្សានៅផ្សាយព័ត៌មានអំពីការដឹកជញ្ជូនឈើ

**១៥ វិច្ឆិកា — ស្ទឹងត្រែង**

អ្នកសារព័ត៌មានអនឡាញម្នាក់ហាមមិនឲ្យរាយការណ៍ព័ត៌មានពីបញ្ហាបរិស្ថានដែលប៉ះពាល់ដល់មុខមាត់អាជ្ញាធរ

**៨ វិច្ឆិកា — បាត់ដំបង**

អ្នកសារព័ត៌មានរងការគំរាមកំហែងវិធានការច្បាប់ពីអភិបាលស្រុក ចំពោះការរាយការណ៍ព័ត៌មានពីសំណង់ខុសច្បាប់

**២៣ តុលា — បាត់ដំបង**

អ្នកសារព័ត៌មានអនឡាញនៅខេត្តបាត់ដំបងរងការគំរាមកំហែងពីមន្ត្រីនគរបាលពេលចុះថតរូប

**១៨ តុលា — ពោធិ៍សាត់**

ប្រព័ន្ធផ្សព្វផ្សាយអនឡាញចំនួនពីរ រងការគំរាមកំហែងដោយចំណាត់ការផ្លូវច្បាប់

**១០ តុលា — ព្រះវិហារ**

អ្នកសារព័ត៌មានអនឡាញរងបណ្ដឹង និងត្រូវចោទពីបទផ្សាយព័ត៌មានមិនពិត

# ឧប្បត្តិហេតុរាយការណ៍ក្នុងត្រីមាសនេះ

## ១. ចាងហ្វាងសារព័ត៌មាន អនឡាញ ជាប់ពន្ធនាគារពីបទចោទថាបានទន្រ្ទានដីព្រៃរបស់រដ្ឋ




ចាងហ្វាងសារព័ត៌មានDN Peace News លោកគឹម ដែន

រូបពីហ្វេសប៊ុក

*ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ ខេត្តស្ទឹងត្រែង*

កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៣ លោក គឹម ដែន ចាងហ្វាងសារព័ត៌មានអនឡាញ DN Peace News នៅក្នុងខេត្តស្ទឹងត្រែង ត្រូវបានកម្លាំងអាវុធហត្ថចាប់ខ្លួន ដោយចោទប្រកាន់ពីបទទន្រ្ទានដីព្រៃរបស់រដ្ឋដើម្បីកាន់កាប់ ដែលបានប្រព្រឹត្តកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩។

កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ តុលាការខេត្តស្ទឹងត្រែង បានកាត់ទោសលោក ដែន ឲ្យជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ ពីបទចោទថា បានទន្រ្ទានដីរដ្ឋនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។ តាមដីកាចាប់ខ្លួនចេញថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ សាលក្រមនៃសំណុំរឿងនេះត្រូវបានសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំតម្កល់ចាត់ទុកជាបានការនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣។

ប្រពន្ធរបស់លោក ដែនបាននិយាយថា នៅថ្ងៃដែលប្តីអ្នកស្រីត្រូវបានចាប់ខ្លួន ប្តីអ្នកស្រីបានទទួលទូរស័ព្ទពីមន្ត្រីកងរាជអាវុធហត្ថខេត្តម្នាក់ ដោយអញ្ជើញឲ្យប្តីអ្នកស្រី ចូលរួមក្នុងពិធីជប់លាងឡើង ឋានន្តរស័ក្តិរបស់មន្ត្រីរូបនោះ នៅសណ្ឋាគារសុខ សម្បត្តិ នៅទីរួមខេត្តស្ទឹងត្រែង ។ ប៉ុន្តែផ្ទុយទៅវិញ ប្តីអ្នកស្រីត្រូវបាននាំទៅកាន់ទីបញ្ជាការកងរាជអាវុធហត្ថខេត្ត ហើយត្រូវបញ្ជូនទៅពន្ធនាគារភ្លាមៗតែម្តង។

ទាំងកិរិយារបស់លោក ដែន និងលោក សុវណ្ណ ដារ៉ាវុធ ចាងហ្វាងរងនៃសារព័ត៌មាន DN Peace News បាននិយាយថា លោក ដែន ធ្លាប់បានឈូសឆាយដីព្រៃ កាលពីឆ្នាំ ២០១៩ មុនពេលគាត់ចូលធ្វើការជាអ្នកសារព័ត៌មានអនឡាញ ប៉ុន្តែក្រោយមកលោកបានប្រគល់ដីនោះឱ្យរដ្ឋវិញ នៅឆ្នាំដដែលនោះ។

លោក សុវណ្ណ ដារ៉ាវុធបានថ្លែងថា លោក ដែន ថ្មីៗនេះបានរាយការណ៍ព័ត៌មានអំពីការកាប់ឈើខុសច្បាប់ជាច្រើនករណីក្នុងខេត្ត ស្ទឹង ត្រែង។

លោក សុវណ្ណ ដារ៉ាវុធបានឲ្យដឹងថា មុនពេលលោក ដែន

*ត្រូវបានចាប់ខ្លួន ដែនបានប្រាប់គាត់ថា កាលពីខែមេសា ឆ្នាំ២០២៣ ចៅក្រមស៊ើបសួរតុលាការខេត្តស្ទឹងត្រែង បានប្រាប់ឲ្យ ដែនបង់ប្រាក់៥០លានរៀល (ប្រមាណ ១២ ០០០ដុល្លារ) ជាថ្នូរនឹងការមិនចាប់ខ្លួន។ លោកជឿថា ការចោទប្រកាន់មកលើដែនជារូបភាពនៃការគំរាមកំហែង។ លោកបន្តថា ៖«ការងារអ្នកសារព័ត៌មានតែងតែ ប៉ះពាល់ដល់អាជ្ញាធរ និងអ្នកដែលប្រព្រឹត្តខុស ហើយខ្ញុំជឿថាករណីនេះជាការបំភិតបំភ័យជាជាងការអនុវត្តច្បាប់» ។*

*លោក ចិក ចិត្រា អ្នកសម្របសម្រួលអង្គការសិទ្ធិមនុស្សអាដហុក ប្រចាំខេត្ត ស្ទឹងត្រែង ដែលបានស៊ើបអង្កេត លើករណីនេះបានប្រាប់ខេមបូចាថា លោកដែន បានប្រឈមនឹងបណ្តឹងជាច្រើនករណី បន្ទាប់ពីលោកបាន រាយការណ៍ពីបញ្ហារស៊ើបនៅក្នុងខេត្ត។*

**ប្រភេទនៃការយាយី ៖** *ការគំរាមកំហែងផ្លូវច្បាប់*

**ប្រភព ៖** *ខេមបូចាសម្ភាសជាមួយភរិយារបស់លោក គឹម ដែន លោក សុវណ្ណដារ៉ាវុធ ចាងហ្វាងរងនៃ* DN Peace News *និងមន្ត្រីអាដហុកប្រចាំខេត្តស្ទឹងត្រែង*

## ២. ចាងហ្វាងសារព័ត៌មាន អនឡាញត្រូវបានចាប់ឃុំខ្លួនពីបទលួចចូលទៅក្នុងប្រព័ន្ធទិន្នន័យ

*ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ រាជធានីភ្នំពេញ*

*កាលពីថ្ងៃទី៤ ខែធ្នូឆ្នាំ២០២៣ លោក នួន មេសា ចាងហ្វាងទូរទស្សន៍អនឡាញ CNM ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ ក្រោមបទចោទប្រកាន់ថាបានលួចចូលដោយខុសច្បាប់ទៅក្នុងប្រព័ន្ធប្រព្រឹត្តកម្មស្វ័យប្រវត្តិនៃទិន្នន័យ ។ ប៉ុន្តែលោក ត្រូវបានដោះលែងឲ្យនៅក្រៅឃុំនៅថ្ងៃទី ១៤ ខែធ្នូ ក្រោយពីត្រូវបានឃុំឃាំងនៅពន្ធនាគារព្រៃសរយៈពេល១០ថ្ងៃ។*

*លោកត្រូវបានដោះលែងឲ្យនៅក្រៅឃុំបន្ទាប់ពីក្រសួងព័ត៌មានបានចាត់តាំងមេធាវីពីររូបឲ្យការពារក្តីឲ្យលោក កាលពីថ្ងៃទី១២ ខែធ្នូ ដែលបានស្នើសុំឲ្យលោកបាននៅក្រៅឃុំ។*

*លោក មេសា ត្រូវបាននគរបាលចាប់ខ្លួនកាលពីវេលាម៉ោងប្រមាណ ២ និង៣០នាទី រសៀលថ្ងៃទី៤ ធ្នូ នៅក្បែរ ហាងកាហ្វេមួយក្នុងរាជធានីភ្នំពេញ ។ លោកបានធ្វើដំណើរទៅទីនោះដើម្បីជួបតំណាងម្នាក់នៃក្រុមហ៊ុនមួយ ដែលមិនបញ្ជាក់ឈ្មោះដើម្បីផ្ទៀងផ្ទាត់ឯកសារ ដែលត្រូវបានអះអាងថា មានប្រភពមកពីក្រុមហ៊ុនពាក់ព័ន្ធនឹង អំពើពុករលួយ។ នេះបើតាមប្អូនប្រុសលោកមេសា គឺលោក នួន ណាក់ ដែលបានប្រាប់មកខេមបូចា នៅថ្ងៃទី៦ ខែធ្នូ គឺពីរថ្ងៃក្រោយលោក មេសា ត្រូវបានចាប់ខ្លួន។*

*លោក ណាក់ បាននិយាយថា បន្ទាប់ពីបងប្រុសរបស់លោកទទួលបានឯកសារហើយ គាត់ក៏បានទាក់ទងទៅ ក្រុមហ៊ុនដើម្បីផ្ទៀងផ្ទាត់ ប៉ុន្តែខាងក្រុមហ៊ុនបានបដិសេធនិយាយតាមទូរស័ព្ទ។*

*លោកបន្តថា បីថ្ងៃក្រោយមក ក្រុមហ៊ុនបានទូរស័ព្ទទៅបងប្រុសរបស់លោកឲ្យមកជួបគ្នាផ្ទាល់នៅហាងកាហ្វេមួយក្នុង សង្កាត់បឹងកេងកង។ ពេលមកដល់ក្បែរហាងកាហ្វេភ្លាម ស្រាប់តែត្រូវបានចាប់ខ្លួនដោយគ្មានការពន្យល់ឡើយ។*

មុនពេលជួបគ្នា លោក មេសា បានថតសំឡេងនៃការសន្ទនារវាងខ្លួនគាត់ និងបុរសម្នាក់ ដែលត្រូវបានអះអាងថាជាតំណាងក្រុមហ៊ុនដើម្បីជួបគ្នានៅហាងកាហ្វេមួយ។ ក្នុងការសន្ទនាសារជាសំឡេងដែលមានរយៈពេល៤នាទី លោក មេសា បាននិយាយថា លោកកំពុងធ្វើដំណើរទៅជួបបុរសម្នាក់ ដែលគាត់អះអាងថា ជានាយកក្រុមហ៊ុន លី ឈួង ដើម្បីផ្ទៀងផ្ទាត់ប្រភពឯកសារដែលលោកបានទទួល។ ក្នុងសំឡេងនោះ លោក មេសា បានអះអាងថា លោកគ្មានចេតនាទៅជំរិតទារប្រាក់ពីក្រុមហ៊ុននោះទេ។ សំឡេងនោះត្រូវបានគេចែករំលែកនៅលើបណ្តាញសង្គមប៉ុន្មានថ្ងៃបន្ទាប់ពីលោក មេសា ត្រូវបានចាប់ខ្លួន ប៉ុន្តែក្រោយមកវាត្រូវបានលុបចោលវិញ។

ទោះជាយ៉ាងណាក៏ដោយ ក្រោយពីការដោះលែងឲ្យនៅក្រៅឃុំ លោក មេសា បាននិយាយក្នុងវីដេអូបង្ហោះលើហ្វេសប៊ុក នៅថ្ងៃទី១៤ ខែធ្នូថា ឯកសារជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុន លី ឈួង ដែលលោកទទួលបាននោះគឺជាឯកសារក្លែងក្លាយ។ លោកបន្តថា លោកបានទទួលឯកសារក្លែងក្លាយពីប្រភពអនាមិកមួយ និងបានស្នើឲ្យសាធារណជន និងអ្នកសារព័ត៌មានបញ្ឈប់ការចែកចាយសារសំឡេងនោះទៀត ឬនឹងត្រូវទទួលខុសត្រូវដោយខ្លួនឯង។

**ប្រភេទនៃការយាយី៖** *ការគំរាមកំហែងផ្នែកច្បាប់*

**ប្រភព**:

1. http://tinyurl.com/2bk288a9
2. *ខេមបូចាសម្ភាសជាមួយប្អូនប្រុសរបស់លោកនួនមេសា*

## ៣. អ្នកសារព័ត៌មានអនឡាញម្នាក់ត្រូវបានគេចាប់ចងដៃ ចងជើង បន្ទាប់ពីរាយការណ៍ព័ត៌មានអំពីការដឹកឈើ

*ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៣ ខេត្តកំពង់ចាម*




កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៣ លោក អ៊ឹម ហាច អាយុ ៣៧ឆ្នាំ ជាអ្នកសារព័ត៌មានអនឡាញមកពីសារព័ត៌មាន សាន ព្រហ្ម ត្រូវបានចាប់ចងដៃ ជើង នឹងខ្សែដោយមនុស្សមួយក្រុមនៅខេត្តកំពង់ចាម ហើយក្រោយមកគាត់ត្រូវបានបញ្ជូនទៅអធិការស្រុកជើងព្រៃដើម្បីសួរចម្លើយ និងបញ្ជូនទៅតុលាការខេត្តដើម្បីសាកសួរបន្ត។

ក្នុងវីដេអូដែលបានបង្ហោះលើហ្វេសប៊ុក លោក ហាច ត្រូវបានគេឃើញដេកលើដីដោយគ្មានអាវ ខណៈដៃ និងជើងគាត់ត្រូវបានចងភ្ជាប់នឹងខ្សែ។ លោកហាច ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុក និងតុលាការដំបូងខេត្តកំពង់ចាម ដើម្បីសាកសួរ។

*លោកត្រូវដោះលែងវិញ បន្ទាប់ពីលោកយល់ព្រមសម្របសម្រួលជាមួយក្រុមមនុស្សដែលចាប់លោកចង។*

*មុនពេលរងនូវហិង្សានេះ លោកហាច បានផ្សាយផ្ទាល់វីដេអូតាមបណ្ដាញសង្គមនិយាយអំពីការដឹកជញ្ជូនឈើនៅតាមផ្លូវ។*

*បើយោងតាមរដ្ឋបាលខេត្តកំពង់ចាម លោក ហាច ត្រូវបានមនុស្សចំនួន៤នាក់ ចាប់ខ្លួននៅភូមិប៉ាណា ឃុំសូទិប ស្រុកជើងព្រៃ បន្ទាប់ពីលោកបានចូលទៅក្នុងទីតាំងឯកជនមួយ ដើម្បីថតរូបឈើ ដោយគ្មានការអនុញ្ញាត។*

*លោក ហាច ជាអតីតអ្នកយកព័ត៌មានឲ្យទូរទស្សន៍អនឡាញ CNM ប៉ុន្តែលោកបានប្ដូរទៅធ្វើជាអ្នកសារព័ត៌មានឲ្យអង្គភាពសារព័ត៌មាន សាន ព្រហ្មវិញ។ ទោះយ៉ាងណានេះក្ដី CNM TV បានបញ្ជាក់ក្នុងលិខិតមួយថ្ងៃក្រោយថ្ងៃកើតហេតុថា លោកហាចត្រូវបានបណ្ដេញចេញពី CNM TV។ តាមរដ្ឋបាលខេត្ត លោក ហាច នៅមិនទាន់បានចុះឈ្មោះជាអ្នកសារព័ត៌មានឲ្យអង្គភាពណាមួយនៅឡើយទេ។*

*ចាងហ្វាងសារព័ត៌មាន សាន ព្រហ្មបានប្រាប់ខេមបូចាថា លោកហាចត្រូវបានបណ្ដេញចេញពីអង្គភាពតាំងពីមុនពេលកើតហេតុម្ទេះ តែលោក ហាច អះអាង វាកើតឡើងក្រោយពេលកើតហេតុ។ លោកហាចថែមទាំងបង្ហាញកាតអ្នកសារព័ត៌មានចេញដោយអង្គភាពសារព័ត៌មាន សាន ព្រហ្ម ដែលមានសុពលភាពរហូតដល់ខែមិថុនាឆ្នាំ២០២៤។*

*លោកហាចនិយាយថា បច្ចុប្បន្នលោកកំពុងបម្រើការឲ្យអង្គភាពសារព័ត៌មានអនឡាញថ្មីមួយឈ្មោះ ICD TV ហើយកំពុងតែសុំកាតអ្នកសារព័ត៌មានក្រសួងសារព័ត៌មាន។*

**ប្រភេទនៃការយាយីៈ ហិង្សាលើរាងកាយ**

**ប្រភពៈ** *ខេមបូចា សម្ភាសជាមួយលោក ហាច និងលោក សាន ព្រហ្ម។*

## ៤-អ្នកសារព័ត៌មានត្រូវបានហាមកុំឲ្យរាយការណ៍ព័ត៌មានពីបញ្ហាបរិស្ថានដែលប៉ះពាល់ដល់មុខមាត់អាជ្ញាធរ

*ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខេត្តស្ទឹងត្រែង*

*កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក អ៊ាន គឹមហឿន អ្នកយកព័ត៌មានទូរទស្សន៍ហង្សមាសប្រចាំខេត្តស្ទឹងត្រែង ត្រូវបានប្រធានមន្ទីរបរិស្ថានខេត្តប្រាប់កុំឱ្យរាយការណ៍ព័ត៌មានអំពីបញ្ហាបរិស្ថានដែលប៉ះពាល់ដល់មុខមាត់អាជ្ញាធរ។*

*រឿងនេះកើតឡើងបន្ទាប់ពីលោក គឹមហឿន បានរាយការណ៍អំពីភាពបរាជ័យរបស់អាជ្ញាធរស្រុកក្នុងការចាប់ខ្លួនអ្នកកាប់ឈើខុសច្បាប់នៅក្នុងស្រុក បុរីអូរស្វាយ សែនជ័យ។*

*លោក គឹម ហឿន បានផ្សាយព័ត៌មាននេះនៅលើកម្មវិធីទូរទស្សន៍ហង្សមាស ហើយបានយកមកបង្ហោះលើបណ្ដាញសង្គមហ្វេស ប៊ុក ផ្ទាល់ខ្លួនថែមទៀត។ អាជ្ញាធរបានប្រាប់ឲ្យលោកលុបអត្ថបទចេញពីហ្វេសប៊ុករបស់គាត់ តែគាត់បានបដិសេធ។*

**ប្រភេទនៃការយាយី៖ ការគំរាមកំហែងដោយពាក្យសំដី**

**ប្រភព៖** *ខេមបូចាបានសម្ភាសជាមួយលោក អ៊ាន គឹមហឿន*

## ៥-អ្នកសារព័ត៌មានរងការគំរាមកំហែងវិធានការច្បាប់ពីអភិបាលស្រុក ចំពោះការរាយការណ៍ព័ត៌មានពីសំណង់ខុសច្បាប់

*ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខេត្តបាត់ដំបង*

*កាលពីថ្ងៃទី៨ ខែវិច្ឆិកា អ្នកយកព័ត៌មានកោះសន្តិភាព លោក ឆោម ពិសម័យ ត្រូវបានអភិបាលស្រុកឯកភ្នំ ខេត្តបាត់ដំបង គំរាមចាត់វិធានការច្បាប ់បន្ទាប់ពីលោកបានរាយការណ៍ព័ត៌មានពីសំណង់ដែលអះអាងថា បានសង់បំពានចូលស្ទឹងសង្កែ។*

*ព័ត៌មាននោះបានរិះគន់ការសម្រេចរបស់អភិបាលស្រុកក្នុងការអនុញ្ញាតឱ្យមានការសាងសង់សំណង់ដោយចាក់ដីចូលទៅផ្នែកខ្លះនៃមាត់ស្ទឹង។*

*លោកត្រូវបានអាជ្ញាធរស្រុកប្រាប់ថា លោកអភិបាលស្រុកកំពុងស្វែងរកភស្តុតាងដើម្បីប្ដឹងលោកពីបទផ្សព្វផ្សាយព័ត៌មានមិនពិត។ លោកបាននិយាយថា បន្ទាប់ពីរាយការណ៍ព័ត៌មានរួច មានអ្នកទូរស័ព្ទមកលោកដោយផ្ដល់ប្រាក់ជាថ្នូរនឹងការដកអត្ថបទចេញ ប៉ុន្តែលោកបានបដិសេធ។*

*សេចក្ដីបំភ្លឺរបស់អាជ្ញាធរស្រុក ដែលបានបង្ហោះលើទំព័រហ្វេសប៊ុក បានបដិសេធរបាយការណ៍នេះ ដោយអះអាងថាជាព័ត៌មានក្លែងក្លាយ។*

**ប្រភេទនៃការយាយី៖ ការគំរាមកំហែងផ្នែកច្បាប់**

**ប្រភព៖** http://tinyurl.com/2aav3hj5 *និង សម្ភាសដោយបណ្ដាញរបស់ខេមបូចា ដែលអាចជឿជាក់បាន*



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបាត់ដំបង
រដ្ឋបាលស្រុកឯកភ្នំ
លេខ..........

ថ្ងៃអង្គារ ៩កើត ខែ អស្សុជ ឆ្នាំ ថោះបញ្ចស័ក ព.ស ២៥៦៧
ស្រុកឯកភ្នំ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០២៣

**សេចក្ដីបំភ្លឺព័ត៌មាន**

**រដ្ឋបាលស្រុកឯកភ្នំ ខេត្តបាត់ដំបង** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា៖ កាលពីថ្ងៃទី០៥ នៃខែវិច្ឆិកា ឆ្នាំ២០២៣ មានគណនីហ្វេសប៊ុកឈ្មោះ **ឆោម ពិសម័យ** បានធ្វើការផ្សព្វផ្សាយ នូវព័ត៌មានមិនពិត ពុំមានប្រភពច្បាស់លាស់ និងត្រឹមត្រូវមកលើ ថ្នាក់ដឹកនាំស្រុក ដែលមានខ្លឹមសារទាំងស្រុងថា " **ពូគេថា លោកចៅហ្វាយស្រុកឯកភ្នំ បើកភ្លើងខៀវឱ្យជាងកែលក់ម៉ូតូនៅឃុំព្រែកខ្ពប ឃុំខ្ពប សាងសង់សំណង់លើលោកយកដីចំណីជាតិស្ទឹងសង្កែជា ផ្លូវនិងប្រាក់សំណូកចំនួន ៣ ... ស្មែកចាំពិតឡូបផ្ទ** " និងការផ្សាយព័ត៌មានរបស់ហ្វេសប៊ុកផេកឈ្មោះ **១០ Buzz ដែលមានខ្លឹមសារថា «ឃុំព្រែកខ្ពបត្រូវមេដៃ»** ដោយចោទប្រកាន់មកលើថ្នាក់ដឹកនាំស្រុក ។ ករណីនេះរដ្ឋបាលស្រុកឯកភ្នំ សូមធ្វើការស្រាយបំភ្លឺជូនថ្នាក់ដឹកនាំខេត្ត និង សាធារណជនជ្រាបតទៅ ៖ ករណីសាងសង់រោងដែក ប្រក់សង្កសី ទំហំ ១០ម៉ែត្រ x ២៥ម៉ែត្រ លើលោកលើដីចំណីស្ទឹងសង្កែនេះ គឺបិតនៅភូមិខ្វិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ របស់ឈ្មោះ **តាន់ ប៊ុនធឿន** ក្រោយមក **តាន់ ប៊ុនធឿន** ក៏ប្រគល់ទីតាំងនេះឱ្យឈ្មោះ **ខែន សុខេង** ត្រូវជាក្មួយគ្រប់គ្រងជំនួសវិញ ។ ក្រោយពីក្រុមការងារចុះត្រួតពិនិត្យសំណង់ដោយគ្មានច្បាប់អនុញ្ញាតរបស់រដ្ឋបាលស្រុក បានចុះទៅជួបជាមួយម្ចាស់សំណង់ និងបានធ្វើកំណត់ហេតុបញ្ឈប់ការសាងសង់លើកទី១ នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២៣ ដោយបានឱ្យម្ចាស់សំណង់រុះរើ ឱ្យដូចសភាពដើមវិញ។ ប៉ុន្តែសាមីខ្លួននៅតែបន្តសាងសង់ ក្រុមការងារក៏ចុះទៅធ្វើកំណត់ហេតុបញ្ឈប់ជាលើកទី ២ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ប៉ុន្តែករណីម្ចាស់សំណង់មិនព្រមបញ្ឈប់ទៀត នៅតែបន្តការសាងសង់ដដែល ។ ករណីមិនព្រមបញ្ឈប់ការសាងសង់នេះ នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០២៣ រដ្ឋបាលស្រុកក៏បានចេញលិខិតបញ្ឈប់ការសាងសង់នេះភ្លាមៗ ដោយឱ្យម្ចាស់សំណង់ខាងលើរុះរើចេញជាបន្ទាន់ បើមិនគោរពតាមការណែនាំខាងលើ រដ្ឋបាលស្រុកនឹងចាត់វិធានការតាមផ្លូវច្បាប់ ។ បើទោះបីយ៉ាងនេះក្ដី ក៏ការសាងសង់នៅតែល្មើសនឹងបម្រាម ហើយនៅតែបន្តការសាងសង់ដដែល ដោយមិនខ្លាចចំពោះវិធានការរបស់រដ្ឋបាលស្រុកឡើយ ទើបនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ២០២៣ ក្រុមការងារសហការជាមួយកងកម្លាំងអធិការនគរបាលស្រុក ចុះធ្វើការបញ្ឈប់ និងដកហូតសម្ភារៈរបស់ជាងមួយចំនួនមករក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកផងដែរ ។

ដូចនេះ ដើម្បីជៀសវាងកុំឱ្យសាធារណជនមានការភាន់ច្រឡំនូវព័ត៌មានបំភ្លៃការពិត និងជាការបំផុសបំផុលបង្កឱ្យសាធារណជនមានការយល់ច្រឡំមកលើរូបថ្នាក់ដឹកនាំស្រុក រដ្ឋបាលស្រុកសូមធ្វើការបដិសេធនូវរាល់សកម្មភាព និងខ្លឹមសារនៃការបង្ហោះរបស់ម្ចាស់គណនីហ្វេសប៊ុកឈ្មោះ **ឆោម ពិសម័យ** នេះទាំងស្រុង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាទទួលជ្រាបជាព័ត៌មាន។

អភិបាលស្រុក

*Clarification letter issued by Ek Phnom District administration dated November 7, 2023.*

## ៦. អ្នកសារព័ត៌មានអនឡាញនៅខេត្តបាត់ដំបងរងការគំរាមកំហែងពីមន្ត្រីនគរបាលពេលចុះថតរូប

*ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ខេត្តបាត់ដំបង*

*កាលពីយប់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ លោកភី វិសិត្រ និពន្ធនាយករងរបស់សារព័ត៌មាន PCN ដែលជាប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញក្នុងខេត្តបាត់ដំបង ត្រូវបានបុរសម្នាក់ ដែលគេស្គាល់ថាជាមន្ត្រីនគរបាលខេត្តបាត់ដំបង បានគំរាមកំហែងដោយពាក្យសំដី។*

*ហេតុការណ៍នេះបានកើតឡើង ខណៈលោក វិសិត្រ កំពុងថតរូបនិងវីដេអូនៃរថយន្តដឹកទំនិញលើសទម្ងន់ ដែលបង្កការខូចខាតផ្លូវក្នុងខេត្ត។*

*វិសិត្រ និយាយថា នៅវេលាម៉ោងប្រហែល៩ និង ៣០នាទីយប់ មានឡានដឹកទំនិញមួយគ្រឿងដែលផ្ទុកលើសទម្ងន់បានជាប់ផុង ដែលបណ្ដាលឲ្យខូចផ្លូវនៅក្នុងខេត្តបាត់ដំបង។ បានបន្តថា នៅពេលដែលគាត់កំពុងថតរូបឡានដែលកំពុងជាប់ផុង ម្ចាស់ឡានដឹកលើសទម្ងន់នោះ ដែលគេស្គាល់ថាអ្នកមន្ត្រីនគរបាលខេត្ត ហើយជាឈ្មួញទំនិញផងនោះ បានដើរចេញពីរថយន្តមួយផ្សេងទៀតមកសួរលោក វិសិត្រថា «ឯងជានរណាបានមកថតរូបហ្នឹង?»*

*ទោះបីដឹងថា វិសិត្រ ជាអ្នកសារព័ត៌មានក៏ដោយ ក៏បុរសរូបនោះនៅតែសួរលោក វិសិត្រ ថា «តើឯងមានការអនុញ្ញាតក្នុងការថតរូបដែរទេ?»*

*លោក វិសិត្រ បានឆ្លើយថា លោកថតរូបនៅលើផ្លូវសាធារណៈ ដូច្នេះលោកមានសិទ្ធិក្នុងការថត។*

*លោក វិសិត្របាននិយាយថា ក្រោយថតរូប និងវីដេអូហើយ លោកបានចាកចេញពីកន្លែងនោះ ហើយបានត្រឡប់ទៅផ្ទះវិញ។ ខណៈលោកកំពុងទទួលទានអាហារពេលល្ងាចជាមួយគ្រួសារនៅផ្ទះដែលមិនឆ្ងាយប៉ុន្មានពីកន្លែងកើតហេតុ មន្ត្រីនគរបាលបានតាមលោកមកដល់ផ្ទះ និងបានថតរូបលោកនៅមុខផ្ទះ ហើយមន្ត្រីនគរបាលរូបនោះបាននិយាយថា៖ «ឯងមានកូនច្រើនគ្រាន់បើ» រួចក៏ដើរចេញ ទៅ។ វិសិត្រ យល់ថា សម្ដីរបស់មន្ត្រីរូបនោះគឺជាការគំរាមមកលើរូបលោក និងគ្រួសារ។*

**ប្រភេទនៃការយាយី៖ ការគំរាមកំហែងដោយពាក្យសំដី**

**ប្រភព៖**

1. http://tinyurl.com/jppkwbhk
2. *សម្ភាសដោយបណ្ដាញរបស់ខេមបូចា*

## ៧. ប្រព័ន្ធផ្សព្វផ្សាយអនឡាញចំនួនពីរ រងការគំរាមកំហែងដោយចំណាត់ការផ្លូវច្បាប់

*ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ពោធិ៍សាត់*

មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ បានព្រមានចាត់វិធានការផ្លូវច្បាប់ចំពោះអង្គភាពសារព័ត៌មានអនឡាញចំនួនពីរក្នុងខេត្ត គឺអង្គភាពសារព័ត៌មាន UMA TV និង សារព័ត៌មានស្ទឹករីទ្ធ។

កាលពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ សារព័ត៌មានទាំងពីរនេះ បានចុះផ្សាយករណីប្រជាពលរដ្ឋមានជម្លោះដីធ្លីក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ អត្ថបទដែលចុះផ្សាយមានចំណងជើងថា៖ «មន្ត្រីមន្ទីរបរិស្ថាន និងនគរបាលស្រុក ចាប់ខ្លួនអនីតិជនយកទៅសួរចម្លើយនៅតុលាការដោយគ្មានដីការ និងមូលហេតុច្បាស់លាស់»។ ប៉ុន្តែរបាយការណ៍នេះត្រូវបានបដិសេធដោយមន្ទីរបរិស្ថាន និងអាជ្ញាធរ តាមរយៈការចេញលិខិតច្រានចោលចុះនៅថ្ងៃទី ២៩ កញ្ញា ឆ្នាំ២០២៣ ដដែលនោះ។

មន្ទីរបរិស្ថានបានរាយការណ៍ករណីនេះទៅក្រសួងព័ត៌មាន ដើម្បីបង្ខំឲ្យអង្គភាពសារព័ត៌មានទាំងពីរនោះ លុបចោលនូវអត្ថបទដែលរិះគន់នោះចេញ។ មន្ទីរបានគំរាមទាមទារឲ្យអង្គភាពសារព័ត៌មានទាំងពីរ បង់ប្រាក់មួយអង្គភាពចំនួន១០០លានរៀល បើមិនព្រមលុបរបាយការណ៍នោះចេញទេ ។ មន្ទីរបានចោទថា អង្គភាពសារព័ត៌មានទាំងពីរបានផ្សព្វផ្សាយព័ត៌មានមិនពិត និងញុះញង់អ្នកដទៃឲ្យកាប់រានដីព្រៃ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានអញ្ជើញ លោក ហ៊ិត សំអឿន និពន្ធនាយករងអង្គភាពសារព័ត៌មាន UMA TV និងលោក សែម សារឿន ចាងហ្វាងសារព័ត៌មានស្ទឹករីទ្ធ ដើម្បីប្រជុំពិភាក្សាពីការអនុវត្តក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន។ ប៉ុន្តែនៅពេលជួបប្រជុំ តំណាងពីក្រសួងព័ត៌មាន បានតម្រូវឲ្យស្ថាប័នសារព័ត៌មានទាំងពីរលុបរបាយការណ៍នោះចេញទៅតាមការស្នើពីមន្ទីរបរិស្ថានខេត្ត។

បន្ទាប់ពីជួបជាមួយតំណាងក្រសួងសារព័ត៌មាន សារព័ត៌មានស្ទឹករីទ្ធ បានយល់ព្រមលុបអត្ថបទចេញ ព្រោះមានការភ័យខ្លាចរឿងដកអាជ្ញាបណ្ណ។ ចំណែក UMA TV បានបដិសេធមិនព្រមលប់អត្ថបទចេញតាមការទាមទាររបស់ក្រសួងព័ត៌មានដោយអះអាងថា របាយការណ៍ខ្លួនត្រឹមត្រូវ និងជាព័ត៌មានពិត។

**ប្រភេទនៃការយាយី៖ ការគំរាមកំហែងដោយពាក្យសំដី**

**ប្រភព៖** *សម្ភាសដោយបណ្តាញខេមបូចា*

## ៨.អ្នកសារព័ត៌មានអនឡាញរងបណ្តឹង និងត្រូវចោទពីបទផ្សាយព័ត៌មានមិនពិត

*ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០២៣ ខេត្តព្រះវិហារ*

*កាលពីខែតុលា លោក អ៊ឹម សាម៉េត អ្នកសារព័ត៌មានអនឡាញរបស់ IPN Watch ប្រចាំខេត្តព្រះវិហារ ត្រូវបានលោកស្រី សេង ឌីឡា ដែលត្រូវបានអះអាងថា ជាឈ្មួញឈើ និងលោក ព្រាប ធឿត ជាមន្ត្រីយោធា ខេត្តព្រះវិហារ ប្តឹងពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍។*

*ពួកគេបានទាមទារឱ្យលោក សាម៉េត បង់ប្រាក់ចំនួន ៨,០០០ ដុល្លារជាថ្នូរនឹងការទម្លាក់ពាក្យបណ្តឹង ។ តុលាការខេត្តព្រះវិហារ បានចេញដីកាចំនួនពីរ និងបង្គាប់ឲ្យសមត្ថកិច្ចនាំខ្លួនលោក សាម៉េត ទៅតុលាការ។ ដីកាទីមួយចេញនៅថ្ងៃទី១០ ខែតុលា ហើយដីកាទី២ ចេញនៅថ្ងៃទី៦ ខែវិច្ឆិកា។*

*លោកបានប្រាប់ខេមបូចាថា លោកមិនបានប្រព្រឹត្តដូចការចោទប្រកាន់តាមពាក្យបណ្តឹងនោះទេ។ នៅក្នុងវីដេអូមួយដែលត្រូវបានបង្ហោះនៅលើទំព័រហ្វេសប៊ុក IPN Watch លោក សាម៉េត បានសម្ភាសគ្រូសារមួយដែលបានអះអាងថា ពួកគេត្រូវបានមន្ត្រីយោធាខេត្តព្រះវិហារបង្ខំឱ្យបង់ប្រាក់ដើម្បីអាចដឹកឈើបាន។*

*ក្នុងវីដេអូមួយទៀត លោក សាម៉េត បានរាយការណ៍ថា ឈ្មោះ សេង ឌីឡា ជាឈ្មួញរកស៊ីឈើ ដ៏លេចធ្លោក្នុងខេត្ត។ លោក ពឿន ប៊ុនធឿន ចាងហ្វាង IPN Watch បាននិយាយថា ស្ថាប័នរបស់លោកឲ្យតម្លៃលើវិជ្ជាជីវៈ ហើយអត្ថបទទាំងអស់ត្រូវបានត្រួតពិនិត្យជាមុន មុននឹងផ្សព្វផ្សាយ។ លោកបានបដិសេធថា សហការីរបស់លោកមិនបានជំរិតទារប្រាក់នោះទេ។*

*ទោះបីយ៉ាងនេះក្តីលោកសាម៉េត បានប្រាប់ខេមបូចាថា ដើមបណ្តឹងបានសម្រេចដកពាក្យបណ្តឹងវិញ ហើយលោកបានបដិសេធក្នុងការផ្តល់ព័ត៌មានអំពីមូលហេតុនៃការដកពាក្យបណ្តឹងនេះ៕*

**ប្រភេទនៃការយាយី៖ ការគំរាមកំហែងផ្នែកច្បាប់**
**ប្រភព៖** *សម្ភាសជាមួយលោក អ៉ឹម សាម៉េត*

# បច្ចុប្បន្នភាពព័ត៌មាន សំខាន់ៗ

## ១. លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ចេញអនុសាសន៍សម្រាប់វិស័យសារព័ត៌មានៈ

កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣ ក្នុងសារលិខិតផ្ញើទៅកាន់វេទិកានិពន្ធនាយកលើកទី២០ ក្រោមប្រធានបទ «វិជ្ជាជីវៈ និងក្រមសីលធម៌សារព័ត៌មាន» លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានលើកឡើងពីសារៈសំខាន់នៃតួនាទីរបស់វិស័យសារព័ត៌មាន និងការងាររបស់អ្នកសារព័ត៌មាន ប៉ុន្តែបានសង្កត់ធ្ងន់ថា វិជ្ជាជីវៈ និងក្រមសីលធម៌អ្នកសារព័ត៌មាននៅមានកម្រិតនៅឡើយ ជាពិសេសក្នុងចំណោមអ្នកសារព័ត៌មានអនឡាញ។ លោក ហ៊ុន ម៉ាណែត បាននិយាយថា ចាំបាច់ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីទទួលបានទំនុកចិត្តពីសាធារណជន។

លោកបន្តថា សមិទ្ធផល និងជោគជ័យរបស់រដ្ឋាភិបាលរហូតមកដល់ពេលនេះ គឺបានមកពីការចូលរួមពីវិស័យសារព័ត៌មាន និងអ្នកសារព័ត៌មាន ដែលធ្វើការជាដៃគូជាមួយរដ្ឋាភិបាល។ លោកបន្តថា រដ្ឋាភិបាលតែងតែលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន ព្រមទាំងលើកទឹកចិត្តឱ្យមានការកសាងសមត្ថភាពបន្ថែមទៀតក្នុងវិស័យសារព័ត៌មាន ក៏ដូចជាការពង្រឹងវិជ្ជាជីវៈ និងក្រមសីលធម៌ផងដែរ។ លោក ម៉ាណែត បានបន្តថា ក្នុងអាណត្តិទី៧ របស់រដ្ឋាភិបាល លោកបានសន្យាដើរតាមឪពុករបស់លោក គឺអតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីលើកស្ទួយវិស័យសារព័ត៌មាន ដោយ ផ្តល់ការលើកលែងពន្ធប៉ាតង់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយអនឡាញប្រភេទធុនតូចទាំងអស់ រយៈពេល៥ឆ្នាំ រហូតដល់ឆ្នាំ២០២៨។ រដ្ឋាភិបាលក៏នឹងផ្តល់ការកាត់បន្ថយកម្រៃអាជ្ញាបណ្ណចំនួន ៥០%ផងដែរ។

អនុសាសន៍របស់នាយករដ្ឋមន្ត្រី ដើម្បីដោះស្រាយការបំពានវិជ្ជាជីវៈ និងក្រមសីលធម៌ និងប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ និងការញុះញង់ៈ

- ចូលរួមថែរក្សាសុខសន្តិភាព ការអភិវឌ្ឍប្រទេសជាតិ និងពង្រឹងលទ្ធិប្រជាធិបតេយ្យ ផ្អែកលើការអនុវត្តច្បាប់ ក្រមសីលធម៌ វិជ្ជាជីវៈឱ្យបានខ្ជាប់ខ្ជួន និងត្រូវលុបបំបាត់ជនឱកាសនិយម ដែលជ្រកក្រោមស្លាកសារព័ត៌មាន។

- ផ្តល់ព័ត៌មានពិតដល់សាធារណជនជាតិ-អន្តរជាតិ អំពីសភាពការណ៍ពិតនៅកម្ពុជា និងផ្សព្វផ្សាយគោលនយោបាយរបស់រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ និងនាំព័ត៌មានពីប្រជាពលរដ្ឋមកកាន់រដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

- ធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងអំពីភាពពិតជាក់ស្តែង និងភាពអសកម្មនៅក្នុងសង្គម ដើម្បីរដ្ឋាភិបាល ដោះស្រាយបញ្ហាចំគោលដៅមានប្រសិទ្ធភាព ស្របតាមកម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាល

- ផ្សព្វផ្សាយអប់រំដល់សាធារណជន អំពីវិធានការបង្ការគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ការជួញដូរមនុស្ស គោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការប្រើប្រាស់គ្រឿងញៀន និងរក្សាសុវត្ថិភាពសង្គម។

- បន្តចូលរួមប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ ដែលមានចរិតបំពុលសង្គម អាចធ្វើឱ្យប្រទេសជាតិអស្ថិរភាពនយោបាយ ចលាចល ភាពវឹកវរ និងបាត់បង់សណ្តាប់ធ្នាប់សង្គម។
- ប្រកាន់ខ្ជាប់ក្រមសីលធម៌ វិជ្ជាជីវៈ ផ្សាយព័ត៌មានពិត មានតុល្យភាព គ្រប់ជ្រុងជ្រោយ ចៀសវាងការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យខូចផលប្រយោជន៍ជាតិ និងបាត់បង់ទំនុកចិត្តពីសាធារណជន។
- បណ្តុះបណ្តាលសមត្ថភាពជំនាញរបស់អ្នកសារព័ត៌មានទាំងបច្ចេកទេស និងវិជ្ជាជីវៈដើម្បីលើកកម្ពស់គុណភាពព័ត៌មាន សណ្តាប់ធ្នាប់វិស័យព័ត៌មាន និងកិត្យានុភាពស្ថាប័នសារព័ត៌មាន។

## ២-អ្នកសារព័ត៌មានអនឡាញម្នាក់ប្រចាំខេត្តកំពង់ធំត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារ២ឆ្នាំ

កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ តុលាការខេត្តកំពង់ធំបានកាត់ទោសលោក សឿ សុជា អ្នកសារព័ត៌មានអនឡាញដែលធ្លាប់បម្រើការនៅ TNM News ឲ្យជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ពីបទជំរិតទារប្រាក់។ ទោះយ៉ាងណាក្តី តុលាការបានសម្រេចដោះលែងលោកឲ្យនៅក្រៅឃុំ។

លោក សុជា ដែលបច្ចុប្បន្នធ្វើការឲ្យសារព័ត៌មានអនឡាញមួយទៀតគឺ ASEAN Daily News បាននិយាយថា ការកាត់ទោសនេះ គឺគ្មានមូលដ្ឋាន និងអយុត្តិធម៌ ព្រោះលោកមិនបានប្រព្រឹត្តបទល្មើសទាំងនោះទេ។

លោក សុជា បានថ្លែងថា៖ «ពាក្យបណ្តឹងត្រូវបានសរសេរតាមការយល់ឃើញរបស់ពួកគេ ហើយមិនមានភស្តុតាងជាក់លាក់នោះទេ។ ខ្ញុំមានភស្តុតាង និងតឹកតាង ប៉ុន្តែគេមិនទទួលយកទេ។ ខ្ញុំមិនយល់ថាហេតុអ្វីទេ»។

លោក សុជា ត្រូវបានកងរាជអាវុធហត្ថខេត្តកំពង់ធំចាប់ខ្លួនម្តងកាលពីថ្ងៃទី១០ ខែឧសភា ហើយបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ ពីបទជំរិតទារប្រាក់។ លោកត្រូវបានដោះលែងវិញនៅថ្ងៃទី១ ខែមិថុនាឆ្នាំ ២០២៣ ។

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុន លោក សែម បូរ៉ា ចាងហ្វាង TNM News បានប្រាប់ខេមបូចា ថា លោក សុជា ទើបតែចាប់ផ្តើមធ្វើការឱ្យអង្គភាពនេះក្នុងឆ្នាំ២០២១ ប៉ុន្តែការចោទប្រកាន់នេះធ្វើឡើងតាំងពីឆ្នាំ២០២០ មកម្ល៉េះ។

លោក បូរ៉ា បាននិយាយថា ការចោទប្រកាន់លោក សុជា កើតចេញពីការរាយការណ៍ព័ត៌មានជាបន្តបន្ទាប់ដែលលោកបានសរសេរអំពីការកាប់ឈើខុសច្បាប់នៅខេត្តកំពង់ធំ។

លោកសុជា ត្រូវបានមនុស្សពីរនាក់ឈ្មោះ ស៊ុន វិចិត្រ និងម្នាក់ទៀតឈ្មោះ ហេង នី ដែលត្រូវបានអះអាងថា ជាឈ្មួញរកស៊ីឈើពីរនាក់នៅខេត្តកំពង់ធំប្តឹងពីបទជំរិតទារប្រាក់។ លោកត្រូវបានចោទប្រកាន់តាមមាត្រា ៣៦៣ និង ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

លោក សុជា និយាយថា ពាក្យបណ្តឹង គឺផ្អែកលើវិក្កយបត្រផ្ទេរប្រាក់ចំនួន ៤លើកតាមភ្នាក់ងារ ដែលដើមបណ្តឹង

បានផ្ញើមកឲ្យលោកដើម្បីធ្វើជាកស្តុតាងថាជាការជំរិតទារប្រាក់។

លោក អ៊ុន ចាន់ថុល មេធាវីរបស់លោក សុជា បានបញ្ជាក់ពីការផ្តន្ទាទោស ដោយថ្លែងថា ការសម្រេចប្តឹងឧទ្ធរណ៍ គឺអាស្រ័យលើកូនក្តីរបស់លោក។

លោក ចាន់ថុល បានបន្តថា៖ «វាជាសិទ្ធិរបស់លោក សឿ សុជា ក្នុងការប្តឹងឧទ្ធរណ៍»។

បច្ចុប្បន្នលោក សុជា បានប្តឹងឧទ្ធរណ៍ ដើម្បីរកយុត្តិធម៌។

**ប្រភព៖** *សម្ភាសជាមួយលោក សុជា*

*ព័ត៌មានចុះផ្សាយពីការកាប់ឈើ៖*

1. http://tinyurl.com/yah4sncb
2. http://tinyurl.com/ydyr7cn2
3. http://tinyurl.com/yc3h7nsu
4. http://tinyurl.com/mrwhb7wj
5. http://tinyurl.com/59ze7bay
6. http://tinyurl.com/yc74he2s

## ៣.ក្រសួងបង្កើតក្រុមការងារប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ

ក្រសួងព័ត៌មាននឹងបង្កើតក្រុមការងាររួម ដោយមានសមាជិកមកពីគ្រប់ក្រសួងស្ថាប័នរបស់រដ្ឋាភិបាលដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ។

សេចក្តីសម្រេចនេះបានធ្វើឡើងក្នុងកិច្ចប្រជុំជាមួយអន្តរក្រសួង និងស្ថាប័នចំនួន៣០ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

ក្រុមការងារនឹងផ្លាស់ប្តូរព័ត៌មាន និងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសមិទ្ធផល និងសកម្មភាពរបស់ក្រសួងស្ថាប័ន តាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិ និងឯកជន និងប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត ដែលមានបំណងវាយប្រហារលើក្រសួង ស្ថាប័នរដ្ឋាភិបាល។

ក្រុមការងារនេះនឹងធ្វើការជាមួយក្រុមការងារផ្ទាល់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ដែលដឹកនាំដោយលោក គួច វេងស្រ៊ុន រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដែលគ្រប់គ្រងទំព័រផ្សព្វផ្សាយបណ្តាញសង្គមរបស់លោក ហ៊ុន ម៉ាណែត។

លោក នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មានបាននិយាយថា ក្រសួងព័ត៌មានត្រូវតែជាស្ថាប័នទំនាក់ទំនងសាធារណៈ

*របស់រដ្ឋាភិបាល ហើយដើរតួនាទីជាសំឡេងរបស់រដ្ឋាភិបាល។*

*តាមរយៈការងារនេះលោករដ្ឋមន្ត្រី បានស្នើដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផ្តល់អត្ថបទ ខ្លឹមសារ រូបភាព និងវីដេអូ ដើម្បីប្រើប្រាស់ជាឧបករណ៍ក្នុងការលើកកម្ពស់ឲ្យបានទូលំទូលាយនូវទំនុកចិត្តរបស់រដ្ឋាភិបាល និងការពិតរបស់រដ្ឋាភិបាល។*

**ប្រភព៖** https://www.information.gov.kh/articles/115353

## ៤- កាសែតជាភាសាខ្មែរបានបិទទ្វារ បន្ទាប់ពីដំណើរការអស់រយៈពេលបីទសវត្សរ៍

*បន្ទាប់ពីផ្អាកការបោះពុម្ពរយៈពេលបីឆ្នាំរួចមក កាសែតរស្មីកម្ពុជា ដែលជាកាសែតភាសាខ្មែរចំណាស់ជាងគេក្នុងប្រទេស បានបិទគេហទំព័ររបស់ខ្លួនជាផ្លូវការហើយ។ ដំណើរការបោះពុម្ពបានបញ្ចប់នៅចុងឆ្នាំ ២០១៩ បន្ទាប់ពីបោះពុម្ពផ្សាយក្នុងប្រទេសកម្ពុជាអស់រយៈពេលប្រមាណ៣០ ឆ្នាំ។ កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣ កាសែតរស្មីកម្ពុជា បានប្រកាសបញ្ឈប់បុគ្គលិកជាង៣០នាក់ រួមទាំងបុគ្គលិកជាស្រី៥នាក់ផងដែរ។ នៅថ្ងៃបន្ទាប់មកកាសែតនេះបានបិទអនឡាញរបស់ខ្លួនរួមទាំងគេហទំព័រព័ត៌មាន និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ។ លោក ទាវ សារៈមុន្នី និពន្ធនាយកកាសែតរស្មីកម្ពុជា បាននិយាយថា មូលហេតុចម្បងនៃការបិទ គឺទាក់ទងនឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ។*

**ប្រភព៖** http://tinyurl.com/29m34fm5

# ទំនាក់ទំនង

+855 (0)23 88 23 11

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ